ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី 29 ខែ មិនា ឆ្នាំ២០១៦។

ADB **ធនាគារអភិវឌ្ឍន៍អាស៊ី**

# ប្រទេសកម្ពុជា ៖ គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យតាមខេត្ត

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យតាមខេត្ត |
| លេខគម្រោង | 48158-001 |
| ប្រទេស | កម្ពុជា |
| ស្ថានភាពគម្រោង | អនុម័ត |
| ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ | ជំនួយបច្ចេកទេស |
| ប្រភពមូលនិធិ/ចំនួនទឹកប្រាក់ | TA 8982-CAM: គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យតាមខេត្ត<br>មូលនិធិពិសេសសម្រាប់ជំនួយបច្ចេកទេស ២០០.០០០ ដុល្លារអាមេរិក |
| របៀបវារៈយុទ្ធសាស្ត្រ | កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពផ្នែកបរិស្ថាន<br>កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា |
| កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ | អភិបាលកិច្ច និងការអភិវឌ្ឍន៍សមត្ថភាព<br>ដំណោះស្រាយផ្នែកចំណេះដឹង<br>ភាពជាដៃគូ<br>ការអភិវឌ្ឍន៍វិស័យឯកជន |
| វិស័យ/អនុវិស័យ | ទឹក និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាតំបន់ទីក្រុងដទៃទៀត ៖ គោលនយោបាយសម្រាប់តំបន់ទីក្រុង ការអភិវឌ្ឍន៍ស្ថាប័ន និងការអភិវឌ្ឍន៍សមត្ថភាព អនាម័យតំបន់ទីក្រុង ការផ្គត់ផ្គង់ទឹកនៅតំបន់ទីក្រុង |
| សមធម៌យេនឌ័រ និងការបញ្ជ្រាបយេនឌ័រ | ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព |

| | |
|---|---|
| ការពណ៌នា | គម្រោងនេះមានសង្គតភាពទៅនឹង (១) យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព (២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៤-២០១៨ និង (៣) ផែនការរបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលភាពជាដៃគូវិស័យឯកជន ពង្រឹងការគ្រប់គ្រងការងារផ្គត់ផ្គង់ទឹករបស់រដ្ឋ និងធ្វើសមាហរណកម្មការផ្គត់ផ្គង់ទឹកនៅតំបន់ទីក្រុង និងការគ្រប់គ្រងបរិស្ថាននៅតំបន់ទីក្រុង។ គម្រោងនេះ គាំទ្រដល់ផែនការប្រតិបត្តិការទឹករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១១-២០២០ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃសេវាផ្គត់ផ្គង់ទឹក។ PPTA នឹងធ្វើការរៀបចំយុទ្ធសាស្ត្រមួយ ព្រមទាំងផែនទីបង្ហាញផ្លូវសម្រាប់វិស័យទឹក និង អនាម័យនៅតំបន់ទីក្រុងរបស់ព្រះរាជាណាចក្រកម្ពុជា។ គម្រោងនេះ ក៏មានសង្គតភាពផងដែរទៅនឹងសរសរស្តម្ភចំនួន២ នៃសរសរស្តម្ភទាំង៣ របស់យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះរួមមានជាអាទិ៍ សរសរស្តម្ភទី១ ដែលសំដៅចំពោះការពង្រឹងការតភ្ជាប់ទំនាក់ទំនងនៅជនបទ ទីក្រុង និងតំបន់ទាំងមូល តាមរយៈការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ និង សេវាផ្គត់ផ្គង់ទឹក និងអនាម័យ និង សរសរស្តម្ភទី៣ ដែលផ្តោតលើកិច្ចគាំទ្រការគ្រប់គ្រងវិស័យសារធារណៈ តាមរយៈការជួយធ្វើវិមជ្ឈការ និងពង្រីកសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ។ |
| សនិទានភាពគម្រោង និងការតភ្ជាប់ទៅនឹង យុទ្ធសាស្ត្រប្រទេស/តំបន់ | ចាប់តាំងពីពេលដែលប្រទេសកម្ពុជាបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ក្រោយពេលបោះឆ្នោតក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានបន្តធ្វើការកសាង និង ធ្វើឱ្យមានភាពធូរស្រាលឡើងវិញពីអតីតកាលដែលរងផលប៉ះពាល់ពីជម្លោះ ដែលរួមមានសង្គ្រាមរយៈពេលជាង២០ឆ្នាំ។ ការវិនិយោគទៅលើវិស័យទឹក និងអនាម័យក្នុងតំបន់ទីក្រុងបានផ្តោតជាចម្បងទៅលើរាជធានីភ្នំពេញដែលជាទីក្រុងធំបំផុត។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង ការអភិវឌ្ឍន៍ស្ថាប័ននៅតាមទីរួមខេត្តបានរងផលប៉ះពាល់ពីការវិនិយោគក្នុងកម្រិតមិនគ្រប់គ្រាន់ ដោយពឹងផ្អែកភាគច្រើនទៅលើជំនួយអភិវឌ្ឍន៍ផ្លូវការពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីជាច្រើនសម្រាប់កិច្ចគាំទ្រហិរញ្ញវត្ថុ ក្នុងនោះរាប់បញ្ចូលទាំងធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ |

ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្គត់ផ្គង់ទឹក និងអនាម័យនៅតំបន់ទីក្រុង ដែលមានលក្ខណៈមិនគ្រប់គ្រាន់ ត្រូវបានគេមើលឃើញយ៉ាងច្បាស់នៅក្នុងប្រទេសទាំងមូល ដែលបណ្តាលឱ្យ (១) រាំងស្ទះចំពោះកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍វិស័យទេសចរណ៍ (២) សេវាគ្មានប្រសិទ្ធភាព និងការផ្គត់ផ្គង់ទឹកដែលមិនទទួលបានចំណូលខ្ពស់ (៣) ការផ្គត់ផ្គង់ទឹក និងការគ្របដណ្តប់ទៅលើកាកសំណល់រាវក្នុងកម្រិតទាប (៤) ការវិចវិលបរិស្ថាន និង (៥) លក្ខខណ្ឌសុខភាពមិនល្អ ជាពិសេស នៅក្នុងសហគមន៍ក្រីក្រ។ នាយកដ្ឋានទឹកស្អាត (DPWS) នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MIH) ទទួលខុសត្រូវចំពោះការសម្របសម្រួល គោលនយោបាយ និងការរៀបចំលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការផ្គត់ផ្គង់ទឹកនៅតំបន់ទីក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា។ អនាម័យនៅតំបន់ទីក្រុង គឺជាការទទួលខុសត្រូវបឋមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) តាមរយៈមន្ទីរដែលជាខ្សែបណ្តោយថ្នាក់ខេត្តរបស់ក្រសួង និង រួមមានការសម្របសម្រួល គោលនយោបាយ និង លិខិតបទដ្ឋានគតិយុត្តិ។ ការបំបែកការទទួលខុសត្រូវចំពោះការផ្គត់ផ្គង់ទឹកនៅតំបន់ទីក្រុង និង អនាម័យតំបន់ទីក្រុង បាននាំឱ្យខ្វះការសម្របសម្រួល និង ការធ្វើសមាហរណកម្មសេវាទូទាំងប្រទេស ហើយនិរន្តរភាពផ្នែកហិរញ្ញវត្ថុនៃបញ្ហាអនាម័យនេះ បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

ផលប៉ះពាល់

## លទ្ធផលគម្រោង

ការពណ៌នាអំពីលទ្ធផល

វឌ្ឍនភាពឆ្ពោះទៅរកលទ្ធផល

## វឌ្ឍនភាពនៃការអនុវត្តន៍

ការពណ៌នាអំពីទិន្នផលគម្រោង

ស្ថានភាពនៃវឌ្ឍនភាពអនុវត្ត (ទិន្នផល សកម្មភាព និង បញ្ហា)

ទីតាំងភូមិសាស្ត្រ

## សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម

ទិដ្ឋភាពផ្នែកបរិស្ថាន

ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត

ជនជាតិដើមភាគតិច

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ក្នុងអំឡុងពេលនៃការរៀបចំគម្រោង

ក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង

## ការទទួលខុសត្រូវក្នុងការអនុវត្តកិច្ច

| | |
|---|---|
| សេវាទីប្រឹក្សា | រាល់ទីប្រឹក្សាទាំងអស់ នឹងត្រូវបង្កលក្ខណៈឱ្យចូលរួមតាមរយៈក្រុមហ៊ុនមួយ ឬ ច្រើន។ ជំនួយបច្ចេកទេសនេះ នឹងតម្រូវឱ្យមានមុខតំណែងចំនួន៤ និង សេវាទីប្រឹក្សាអន្តរជាតិចំនួន ១៦នាក់ក្នុងមួយខែ ព្រមទាំងមុខតំណែងចំនួន ១០ និង សេវាទីប្រឹក្សាជាតិចំនួន ៥០នាក់ក្នុងមួយខែ។ ADB/CDIA នឹងធ្វើការជ្រើសរើស ព្រមទាំងបង្កលក្ខណៈឱ្យទីប្រឹក្សាបានចូលរួមបម្រើការងារ យោងតាមគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីការប្រើប្រាស់ទីប្រឹក្សា (គោលការណ៍ណែនាំឆ្នាំ២០១៣ ដែលមានការកែសម្រួលជាបន្តបន្ទាប់) ព្រមទាំងការរៀបចំដទៃទៀត ដែលមានលក្ខណៈគួរជាទីពេញចិត្តចំពោះធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការជ្រើសរើស និង ការចូលរួមបម្រើការងារពីទីប្រឹក្សាជាតិ។ គេនឹងអនុវត្តវិធីសាស្ត្រជ្រើសរើស ដែលមានមូលដ្ឋានផ្អែកលើគុណភាព និងតម្លៃ ដោយប្រើប្រាស់ផលធៀបរវាងគុណភាព និងតម្លៃ 90:10 អាស្រ័យដោយតម្រូវឱ្យមានគុណភាពបច្ចេកទេសក្នុងកម្រិតមួយខ្ពស់។ ទីប្រឹក្សាក៏នឹងតម្រូវឱ្យធ្វើសំណើបច្ចេកទេសខ្លីៗផងដែរ។ |
| លទ្ធកម្ម | ការដកសាច់ប្រាក់ក្រោមជំនួយបច្ចេកទេសនេះ នឹងត្រូវបានធ្វើឡើងស្របទៅតាមសៀវភៅណែនាំស្តីពីការដកសាច់ប្រាក់ជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ខែឧសភា ឆ្នាំ២០១០ ដែលមានការកែសម្រួលជាបន្តបន្ទាប់)។ ទីប្រឹក្សាអាចធ្វើលទ្ធកម្មឧបករណ៍សម្ភារៈតាមរយៈការទិញដោយយោងទៅតាមគោលការណ៍ណែនាំ ស្តីពីលទ្ធកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (គោលការណ៍ណែនាំឆ្នាំ២០១៥ ដែលត្រូវបានកែសម្រួលជាបន្តបន្ទាប់)។ ឧបករណ៍សម្ភារៈដែលបានធ្វើលទ្ធកម្ម នឹងត្រូវផ្ទេរទៅឱ្យអង្គភាពគ្រប់គ្រងគម្រោងនៅពេលបញ្ចប់ជំនួយបច្ចេកទេសនេះ។ |

## បុគ្គលិកទទួលខុសត្រូវ

| | |
|---|---|
| មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | Michael White |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ (SERD) |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | ផ្នែកអភិវឌ្ឍន៍តំបន់ទីក្រុង និងទឹក នៃ SERD |
| ទីភ្នាក់ងារប្រតិបត្តិ | **ក្រសួងសាធារណការ និងដឹកជញ្ជូន**<br>ជាន់ទី១ អគារខាងលិច<br>កែងមហាវិថីព្រះនរោត្តម និងផ្លូវ ១០៦<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**<br>អគារលេខ ៤៥ មហាវិថីព្រះនរោត្តម (៤១), ១២២០៥<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |

## កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | - |
| បេសកកម្មស្វែងរកការពិត | - |
| កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង (MRM) | - |
| ការអនុម័ត | ២៨ តុលា ២០១៥ |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាព PDS លើកចុងក្រោយ | ០៤ វិច្ឆិកា ២០១៥ |

TA 8982-CAM: គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យតាមខេត្ត

## ព្រឹត្តិការណ៍សំខាន់ៗ

| ការអនុម័ត | ការចុះហត្ថលេខា | ការចូលជាធរមាន | ការបិទ | | |
|---|---|---|---|---|---|
| | | | កំណត់ពីដំបូង | កែសម្រួលឡើងវិញ | ជាក់ស្តែង |
| ២៨ តុលា ២០១៥ | ០៥ មករា ២០១៦ | ០៥ មករា ២០១៦ | ៣១ មករា ២០១៧ | - | - |

| ផែនការផ្តល់ហិរញ្ញប្បទាន/ការប្រើប្រាស់ TA | | | | | | | ការដកសាច់ប្រាក់សរុប | |
|---|---|---|---|---|---|---|---|---|
| ADB | សហហិរញ្ញប្បទាន | សមភាគី | | | | សរុប | កាលបរិច្ឆេទ | ចំនួនទឹកប្រាក់ |
| | | រដ្ឋាភិបាល | អ្នកទទួលផល | អ្នកឧបត្ថម្ភគម្រោង | ផ្សេងៗ | | | |
| 200,000.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 200,000.00 | ២៨ តុលា ២០១៥ | 0.00 |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី មិនផ្តល់ការធានា ឬ ភាពជាតំណាងណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។